មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

**វិចារណកថាព័ត៌មាន**

ភ្នំពេញ ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៣

## មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា សូមថ្កោលទោសចំពោះការរារាំងរបស់អាជ្ញាធរមកលើវេទិកាសាធារណៈដែលរៀបចំដោយ មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) ថ្កោលទោសចំពោះការរារាំងលើវេទិកាសាធារណៈស្តីពីការបោះឆ្នោត ដែលបានរៀបចំដោយ មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (ម.ក.ផ.ឯ) នៅខេត្តបាត់ដំបង កាលពីថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៣ ដូចបានរាយការណ៍ក្នុង *សារព័ត៌មាន ឌឹ ភ្នំពេញ ប៉ុស្តិ៍* (ថ្ងៃសុក្រ ទី២៣ ខែសីហា ឆ្នាំ២០១៣)។ អាជ្ញាធរបានបង្ក្រាបមកលើវេទិកាសាធារណៈ ដោយធ្វើការទប់ស្កាត់មិនឲ្យអ្នកចូលរួមចូលទៅក្នុងផ្ទះរបស់បុគ្គលឯកជនមួយដែលជាកន្លែងរៀបចំវេទិកាសាធារណៈនោះ។ អាជ្ញាធរបានអះអាងថាវេទិកានេះមិនមានច្បាប់អនុញ្ញាត ដោយសារតែអ្នករៀបចំមិនបានសុំការអនុញ្ញាតជាមុន។ ក្នុងច្បាប់កម្ពុជាមិនមានបញ្ញត្តិណាមួយតម្រូវឲ្យមានការសុំការអនុញ្ញាតក្នុងការរៀបចំវគ្គបណ្តុះបណ្តាល និងវេទិកាសាធារណៈបែបនេះទេ។

សិទ្ធិសេរីភាពនៃការជួបប្រជុំត្រូវបានធានាក្នុងមាត្រា ៤១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា ២១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ក.អ.ស.ព.ន) ដែលកម្ពុជាបានឲ្យសច្ចាប័នកាលពីឆ្នាំ១៩៩២។ តាមច្បាប់ទាំងពីរនេះ សិទ្ធិសេរីភាពក្នុងការប្រមូលផ្តុំអាចនឹងមានការរឹតត្បិតមួយចំនួន ដើម្បីការពារនូវសណ្តាប់ធ្នាប់សាធារណៈ សន្តិសុខជាតិ សីលធម៌សង្គម ព្រមទាំងសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ។ ក្នុងករណីនេះ មិនមានភស្តុតាងណាដែលថាការរឹតត្បិតមកលើការជួបប្រជុំ ពោលគឺវេទិកាសាធារណៈដែលបានរៀបចំឡើងដោយ ម.ក.ផ.ឯ ត្រូវបានលើកឡើងត្រឹមត្រូវស្របទៅនឹងមូលដ្ឋានណាមួយដែលបានរៀបរាប់ខាងលើនោះទេ។ ការបង្ក្រាបរបស់មន្ត្រីនគរបាលទៅវិញទេ ដែលជាការរំខានដល់សណ្តាប់ធ្នាប់សាធារណៈ។ ដូច្នេះ សកម្មភាពរបស់អាជ្ញាធរ គឺជាការរំលោភបំពានលើសិទ្ធិសេរីភាពខាងការជួបប្រជុំរបស់ប្រជាពលរដ្ឋខ្មែរ។ តាមរយៈការបំបិទមាត់របស់អ្នករៀបចំវេទិកា និងអ្នកចូលរួមយ៉ាងមានប្រសិទ្ធភាពបែបនេះ ក៏បង្ហាញថាអាជ្ញាធរបានរំលោភបំពានលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិរបស់ប្រជាពលរដ្ឋផងដែរ ដែលសិទ្ធិនេះត្រូវបានការពារនៅក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិ ដោយមានបញ្ញត្តិនៅមាត្រា ៤១ នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៩ នៃ ក.អ.ស.ព.ន។

ការរារាំងរបស់អាជ្ញាធរមកលើវេទិកាសាធារណៈ និងកិច្ចប្រជុំដែលរៀបចំដោយអង្គការមិនមែនរដ្ឋាភិបាល (អង្គការ) នៅកម្ពុជា គឺជារឿងដែលកើតមានជារឿយៗ។ កាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១២ ម.ស.ម.ក បានរៀបចំវគ្គបណ្តុះបណ្តាលមួយស្តីពីសិទ្ធិដីធ្លី ដែលបានធ្វើរួមគ្នាជាមួយនឹងអង្គការដៃគូគឺ សមាគមអាដហុក ការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (សមាគមអាដហុក) នៅក្នុងខេត្តរតនៈគិរី ដែលត្រូវបានរារាំងដោយអាជ្ញាធរមូលដ្ឋាន ដោយអះអាងថា ម.ស.ម.ក និង សមាគមអាដហុក ខកខានមិនបានស្នើសុំការអនុញ្ញាតឲ្យរៀបចំកម្មវិធីនេះ។ យោង

តាមច្បាប់ អង្គការពុំតម្រូវឲ្យស្នើសុំការអនុញ្ញាតក្នុងការរៀបចំវគ្គបណ្តុះបណ្តាលបែបនេះទេ ហើយការពិត ម.ស.ម.ក បានជូនដំណឹងដល់អាជ្ញាធរមុននឹងរៀបចំដោយការគួរសម។ វគ្គបណ្តុះបណ្តាលរួមគ្នានោះដោយថាហេតុ ត្រូវបានបញ្ចប់ ក្នុងក្តីបារម្ភផ្នែកសុវត្ថិភាព ដោយសារតែស្ថានភាពប្រឈមបានកញ្ជ្រោលខ្លាំងឡើងភ្លាមៗ នៅពេលដែលមន្ត្រីនគរបាលម្នាក់បានមកដល់ទីកន្លែងនោះដោយមានកាន់កាំភ្លើងអាកា អឹម ១៦។ រយៈពេលប៉ុន្មានខែក្រោយមក នៅថ្ងៃទី២៤ ខែកញ្ញា អភិបាលស្រុកលំផាត់ ខេត្តរតនៈគិរី បានព្យាយាមហាមឃាត់ ម.ស.ម.ក មិនឲ្យរៀបចំវេទិកាសាធារណៈក្នុងស្រុករបស់លោក ដែលជាថ្មីម្តងទៀតបានអះអាងថា ម.ស.ម.ក មិនមានលិខិតអនុញ្ញាតដែលមានសុពលភាព ទោះបីជាពុំមានការបង្ហាញពីភាពត្រឹមត្រូវតាមផ្លូវច្បាប់ក៏ដោយ។

ឆ្លើយតបទៅនឹងករណីនេះ មន្ត្រីសម្របសម្រួលគម្រោងសេរីភាពបញ្ចេញមតិនៅកម្ពុជា របស់ ម.ស.ម.ក កញ្ញា សន រ៉ាមណា បានមានប្រសាសន៍ថា ៖

*"ការរារាំងដោយអាជ្ញាធរមកលើព្រឹត្តិការណ៍ដែលរៀបចំឡើងដោយអង្គការបែបនេះ មិនមែនជារឿងថ្មីនោះទេនៅកម្ពុជា។ ការបង្ក្រាបដោយកំពលមកលើវេទិកាសាធារណៈ និងវគ្គបណ្តុះបណ្តាល មិនមែនគ្រាន់តែជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរមកលើសិទ្ធិសេរីភាពខាងការជួបប្រជុំ និងបញ្ចេញមតិនោះទេ ប៉ុន្តែក៏ថែមទាំងរារាំងនូវសណ្តាប់ធ្នាប់សង្គម និងបង្កើនហានិភ័យនៃការប្រឈមមុខគ្នាដោយហិង្សាផងដែរ ដែលជាអ្វីដែលអាជ្ញាធរអះអាងថាខ្លួនកំពុងតែប៉ុនប៉ងចង់បង្ការ។ អាជ្ញាធរជាតិ ត្រូវតែធានាថាអាជ្ញាធរមូលដ្ឋានទាំងឡាយមានការយល់ដឹងពីច្បាប់នានាដែលកំពុងតែអនុវត្ត និងសិទ្ធិរបស់ម្ចាស់ឆ្នោតរបស់ខ្លួន ដើម្បីចៀសវាងកុំឲ្យហេតុការណ៍បែបនេះកើតមានឡើងទៀតនាពេលអនាគត"*។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងកញ្ញា សន រ៉ាមណា តាមរយៈទូរសព្ទ +៨៥៥(0) ១៧ ៦៥ ៥៥ ៩១ ឬ អ៊ីម៉ែល** ramanasorn@cchrcambodia.org **ឬកញ្ញា អូឡា ខេលី ទីប្រឹក្សា ម.ស.ម.ក តាមរយៈទូរសព្ទ +៨៥៥(0)៦៧ ៧២ ៧០ ២៥ ឬអ៊ីម៉ែល** orla.kelly@cchrcambodia.org**។**

– ចប់ –

**បណ្ណាធិការ៖**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") បង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០០២ ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

ម.ស.ម.ក ជាសមាជិកនៃដៃគូសន្ទនាអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិ (អាយហ្វិក) ដែលជាបណ្តាញសាកលសម្រាប់សេរីភាពបញ្ចេញមតិ។ ម.ស.ម.ក ក៏ជាសមាជិកនៃអង្គការប្រឆាំងនឹងការធ្វើទារុណកម្ម ពិភពលោក (OMCT) ជាបណ្តាញជួយសង្គ្រោះចំពោះអំពើទារុណកម្ម។

គេហទំព័រសិទ្ធិមនុស្សកម្ពុជា www.sithi.org បានទទួលពានរង្វាន់មូលនិធិនៃការបង្កើតសង្គមព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ ស្ថិតក្នុងប្រភេទ "សិទ្ធិ និងសេរីភាព" និង បានទទួលពានរង្វាន់ផ្នែកទំនាក់ទំនងសម្រាប់ការផ្លាស់ប្តូរសង្គមប្រចាំឆ្នាំ២០១៣ ដែលផ្តល់ជូនដោយមជ្ឈមណ្ឌលទំនាក់ទំនង និងការផ្លាស់ប្តូរសង្គមនៃសាកលវិទ្យាល័យឃ្វីនឡែន ក្នុងរដ្ឋប្រីសបែន ប្រទេសអូស្ត្រាលី។